**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**អគ្គលេខាធិការដ្ឋាន**
**ក្រុមលទ្ធកម្ម**

លេខ: ៣/៥១ កសក.អល.កល

# សេចក្តីជូនដំណឹង
## ស្តីពីការអញ្ជើញចូលរួមពិគ្រោះថ្លៃស្តីពីការផ្គត់ផ្គង់ស្បៀង និងភេសជ្ជៈ ប្រចាំឆ្នាំ២០២៦ របស់អង្គភាពថវិកា នៃអគ្គលេខាធិការដ្ឋាន

អង្គភាពថវិកា នៃអគ្គលេខាធិការដ្ឋាន សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាស ឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជា ឱ្យបានជ្រាបថា អគ្គលេខាធិការដ្ឋាន នឹងដាក់ឱ្យពិគ្រោះថ្លៃជាសាធារណៈដើម្បីជ្រើសរើសទទួលអ្នកផ្គត់ផ្គង់ស្បៀង និងភេសជ្ជៈ ប្រចាំឆ្នាំ២០២៦ របស់អង្គភាពថវិកា នៃអគ្គលេខាធិការដ្ឋាន។

អង្គភាពថវិកា នៃអគ្គលេខាធិការដ្ឋាន បានរៀបចំឯកសារសម្រាប់ ក្រុមហ៊ុន/សហគ្រាស បំពេញដើម្បីចូលរួមពិគ្រោះថ្លៃ និងមានដាក់លក់នៅក្រុមលទ្ធកម្ម របស់អង្គភាពថវិកា នៃអគ្គលេខាធិការដ្ឋាន ដែលមានអាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៦ តទៅរៀងរាល់ម៉ោងធ្វើការ ( ទូរស័ព្ទទាក់ទងលេខ០៦០ ២១ ២១ ៨៣)។

ឯកសារពិគ្រោះថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនក្រុមលទ្ធកម្ម នៃអង្គភាពថវិកា អគ្គលេខាធិការដ្ឋាន យ៉ាងយូរបំផុតត្រឹមថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៦ វេលាម៉ោង០៩:០០។

ការបើកសំណើពិគ្រោះថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមអាសយដ្ឋាន ខាងលើ វេលាម៉ោង០៩:០០ ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៦។

ក្រុមហ៊ុន/សហគ្រាស ដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើពិគ្រោះថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមពិគ្រោះថ្លៃ សូមអញ្ជើញទាក់ទងជាមួយក្រុមលទ្ធកម្ម របស់អង្គភាពថវិកា នៃអគ្គលេខាធិការដ្ឋាន ដើម្បីទិញឯកសារពិគ្រោះថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការពិគ្រោះថ្លៃនេះ។

ថ្ងៃ ចន្ទ ៦រោច ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី៩ ខែមីនា ឆ្នាំ២០២៦

**អគ្គលេខាធិការ**
**និងជាប្រធានក្រុមលទ្ធកម្ម**

**បណ្ឌិត សរ ចិត្រា**

**ចម្លងជូន៖**
- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ឯកសារ កាលប្បវត្តិ